00664458

E9/22

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈជាមួយឧបសម្ព័ន្ធសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>ផ្ញើជូន៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តារ៉ា

ចៅក្រមបំរុង Claudia FENZ

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 04 / 2011
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អនុលោមទៅតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (“ដីកាបង្គាប់”)[1] លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមដាក់ក) បញ្ជីឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងខ) ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាមេធាវីការពារក្តីមិនត្រូវបានតម្រូវ ឬមិនមានលទ្ធភាពជ្រើសរើសនៅពេលនេះនូវឯកសារជាក់លាក់នៅក្នុងបញ្ជីនេះដែលមេធាវីការពារក្តីនឹងយកមកប្រើនៅពេលសវនាការ គ) ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាមេធាវីការពារក្តីមិនអាចផ្តល់ “តារាងនៃភស្តុតាងជាឯកសារ” ចំពោះសម្ភារៈដែលមាននៅក្នុងសំណុំរឿងរួចហើយនោះទេ និងឃ) ជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងថាមេធាវីការពារក្តីនឹងផ្តល់បញ្ជីបឋមនៃឯកសារថ្មី រួមទាំងឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (“SMD”) ផងដែរ ទៅតាមកាលបរិច្ឆេទកំណត់របស់អង្គជំនុំជម្រះសាលាដំបូង ។ ញត្តិនេះត្រូវបានធ្វើឡើងជាចាំបាច់ដើម្បីគោរពតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងកម្រិតមួយដែលអាចធ្វើទៅបាន និងដើម្បីលើកឡើងនូវបញ្ហាជាក់លាក់ទាក់ទងនឹងដីកាបង្គាប់នេះ ហេតុដូច្នេះបញ្ហាទាំងនេះអាចត្រូវបានលើកយកមកពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការខាងមុខនេះ ។

## I សាវតារ

១. នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈមិនឱ្យហួសពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១ នេះទេ:

i) បញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយត្រូវបង្ហាញនូវអត្តសញ្ញាណឱ្យបានសមស្របតាមរយៈលេខឯកសារយោង ចំណងជើង ភាសាដែលមាន ហើយត្រូវពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា ។

ii) បញ្ជីឯកសារថ្មី ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានការពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា និង

iii) “តារាងនៃភស្តុតាងជាឯកសារ” ដែលចង្អុលបង្ហាញនូវភស្តុតាងជាឯកសារ ដែលភាគីនឹង

---

[1] *ករណី ឯក ជា* 00២-១៩-0៩-២00៧-អវតក/អជសង ដីកាបង្គាប់ឱ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ E9, ERN: 00635754-00635759 ។

យកប្រើទាក់ទងនឹងការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ ចំពោះអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងនីមួយៗ[2] ។

២. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់ញត្តិមួយទាក់ទងនឹងដំណើរការជំនុំជម្រះលើសំណុំរឿង ០០២ និងបានស្នើសុំឱ្យផ្អាក់ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង រហូតដល់អង្គជំនុំជម្រះបានដោះស្រាយបញ្ហានេះ[3] ។

៣. នៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១១ ក្រុមការពារក្តី ខៀវ សំផន បានដាក់សំណើសុំពន្យាពេលដាក់បញ្ជីឯកសាររបស់ខ្លួន ដែលតម្រូវដោយដីកាបង្គាប់នេះ[4]។ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យយល់ឃើញថាការអនុវត្តវិធាន ៨០ រំលោភលើ ក) សច្ចធារណ៍នៃនិរទោស ខ) គោលការណ៍ដែលថាបន្ទុកនៃការបង្ហាញភស្តុតាងគឺជាបន្ទុករបស់ព្រះរាជអាជ្ញា គ) សិទ្ធិទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបការពារក្តី និងឃ) សិទ្ធិត្រូវជំនុំជម្រះដោយមិនអូសបន្លាយ ។ មេធាវីការពារស្នើសុំអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យខ្លួនដាក់ឯកសារបន្ទាប់ពីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ការបង្ហាញភស្តុតាងរបស់ពួកគេ និងឱ្យយល់ឃើញថាពេលវេលាកំណត់សម្រាប់ការដាក់ឯកសារនេះ ត្រូវចាប់ផ្តើមគិតចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេចជាភាសាបារាំងរបស់អង្គជំនុំជម្រះលើសំណើរបស់ខ្លួនតែប៉ុណ្ណោះ[5] ។

៤. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់សំណើសុំពន្យាពេលដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់ខ្លួន[6] ។ សំណើរបស់មេធាវីការពារក្តីពន្យល់ថាការតម្រូវនូវបញ្ជីទាំងនេះដែលត្រូវតែដាក់មិនឱ្យលើសពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១ នឹងរំលោភលើសិទ្ធិរបស់ អៀង សារី ដែលត្រូវ

---

[2] ដូចខាងលើ នៅកថាខណ្ឌទី ១២ ។

[3] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/អជសង ញត្តិរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដំណើរការជំនុំជម្រះលើសំណុំរឿង ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណើជាបន្ទាន់សុំផ្អាកដីកាបង្គាប់ដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ E9/3, ERN: 00641756-00641760 ។

[4] *ករណី ខៀវ សំផន* ០០២-១៩-០៩-២០០៧-អវតក/អជសង សំណើសុំបន្ថែមពេលវេលាដើម្បីដាក់ភស្តុតាង ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ E9/6, ERN: 00650206-00650215 ។

[5] ដូចខាងលើ នៅកថាខណ្ឌទី៣៥ ។

[6] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/អជសង សំណើរបស់ អៀង សារី សុំពន្យាពេលបន្ថែមដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ E9/16, ERN: 00655282-00655288 ។

សន្មត់ជាមុនថាគ្មានទោស និងសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តីរបស់គាត់ ។ មេធាវីការពារក្តីស្នើសុំការអនុញ្ញាតឲ្យដាក់បញ្ជីទាំងនេះ បន្ទាប់ពីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញបញ្ជីឯកសាររបស់ពួកគេ ឬជាជម្រើសមួយផ្សេងទៀត មេធាវីការពារក្តីសូមដាក់បញ្ជីទាំងនេះក្នុងរយៈពេល៦០ ថ្ងៃគិតចាប់ពីថ្ងៃអង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងភាគីទាំងអស់ទាក់ទងនឹងរចនាសម្ព័ន្ធនៃការជំនុំជម្រះក្តី និងដីកាសម្រេចលើវិធានបទដែលនឹងត្រូវលើកមកដោះស្រាយ[7] ។

៥. នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១ មេធាវីការពារក្តី នួន ជា បានចូលរួមជាមួយនឹងសំណើនេះ[8] ។

៦. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ មេធាវីការពារក្តី អៀង ធីរិទ្ធ បានចូលរួមជាមួយនឹងសំណើនេះ[9] ។

៧. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ នៅក្នុងសេចក្តីសម្រេចមួយដែលចុះហត្ថលេខាដោយចៅក្រម និល ណុន តែម្នាក់ឯង អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើសុំពន្យាពេលរបស់មេធាវីការពារក្តី[10] ។ មូលហេតុតែមួយគត់ដែលបានផ្តល់សម្រាប់ការបដិសេធនេះ គឺ: "មេធាវីការពារក្តីក្រោយពីបានទទួលនូវការជូនដំណឹងអំពីកាលបរិច្ឆេទចុងក្រោយ ដែលកំណត់ដោយដីការបស់អង្គជំនុំជម្រះចាប់តាំងពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ និងក្រុមមេធាវីការពារក្តីបានចូលមើលសំណុំរឿងចាប់តាំងពីថ្ងៃចាប់ផ្តើមការបំពេញកិច្ចស៊ើបសួរ។ ដូច្នេះមេធាវីការពារក្តីមិនអាចអះអាងថាខ្លួនមិនមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួនបានឡើយ"[11] ។

---

[7] ដូចខាងលើ ។

[8] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/អជសដ ការជូនដំណឹងស្តីពីការចូលរួមនឹងសំណើរបស់ អៀង សារី សុំពន្យាពេលបន្ថែមដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១ E9/16/1, ERN: 00655718-00655719 ។

[9] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/អជសដ ញត្តិរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ផ្តល់ការគាំទ្រដល់ "សំណើរបស់ អៀង សារី សុំពន្យាពេលបន្ថែមដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ E9/16/3, ERN: 00656495-00656496 ។

[10] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/អជសដ សេចក្តីសម្រេចលើសំណើសុំពន្យាពេលដាក់បញ្ជីឯកសារ និងវត្ថុតាង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ E9/16/4, ERN: 00657167-00657169 ។

[11] ដូចខាងលើ ។

II. **ច្បាប់ដែលនៅជាធរមាន**

៨. មាត្រា ៣២១ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងនៅផ្នែកពាក់ព័ន្ធថា:

លើកលែងតែមានបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតំលៃភស្តុតាងដែលគេដាក់ឲ្យខ្លួនមកពិនិត្យដោយផ្អែកលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។

៩. មាត្រា ៣៣៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា:

រហូតដល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត ។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចុះទិដ្ឋការប្រធានសវនាការ និងក្រឡាបញ្ជី ហើយត្រូវភ្ជាប់ក្នុងសំណុំរឿង[12]។

១០. វិធាន ៨៧(១)-(៤) នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") ចែងថា:

១. លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក ។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

២. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងហើយភស្តុតាងទាំងនោះត្រូវឆ្លងកាត់ការដេញដោល ។

៣. អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬ

---

[12] បញ្ជាក់បន្ថែម ។

ប្រសិនបើអង្គជំនុំជម្រះខ្លួនឯង យកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា:

ក. មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ. មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ. មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ. មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ ។

៤. ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣)ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬ ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ។

១១. មាត្រា ៨០(៣) ចែងថា:

អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យភាគីទាំងឡាយដាក់ឯកសារតាមពេលកំណត់មុនពេលសវនាការបឋម រួមទាំងឯកសារដូចខាងក្រោម:

...

ខ) បញ្ជីវត្ថុតាង ដែលភាគីទាំងឡាយមានបំណងប្រគល់ឲ្យសម្រាប់រឿងក្តីនោះដោយមានពិពណ៌នាត្រួសៗអំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាងទាំងនោះ ។

...

00664464



ឃ) បញ្ជីឯកសារថ្មីដោយមានភ្ជាប់សេចក្តីសង្ខេបពីខ្លឹមសារនៃឯកសារនោះ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបញ្ជីឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿងដែលបានកំណត់អត្តសញ្ញាណសមស្រប...

## III. អំណះអំណាង

### ក. បញ្ជីឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង

#### ១. ឯកសារដែលយកមកប្រើដោយ កសចស នៅក្នុងដីកាដំណោះស្រាយ

១២. អង្គជំនុំជម្រះមានបញ្ជីឯកសារយ៉ាងទូលំទូលាយ ដែលត្រូវបានលើកមកសំអាងនៅក្នុងដីកាដំណោះស្រាយ ដែលភ្ជាប់ការចោទប្រកាន់ ឬ ការអះអាងនៅក្នុងដីកាដំណោះស្រាយ ទៅនឹងឯកសារ និងសាក្សី ។ ជាចំណុចចាប់ផ្តើម មេធាវីការពារក្តីស្នើថាឯកសារទាំងអស់នេះ ត្រូវតែបានប្រើដោយភាគីទាំងឡាយ ឬ ដោយអង្គជំនុំជម្រះនៅទូទាំងកិច្ចដំណើរការនីតិវិធី ។ អាស្រ័យហេតុនេះអង្គជំនុំជម្រះពិតមានតារាងឯកសារជាភស្តុតាងយ៉ាងពិតប្រាកដ បើទោះបីមិនស្ថិតនៅក្នុងទម្រង់ជាក់លាក់ដែលមេធាវីការពារក្តីកំពុងស្នើសុំនោះ គឺតារាងភស្តុតាងជាឯកសារ ។

#### ២. សម្ភារៈទាំងអស់នៅក្នុងសំណុំរឿងដែលមិនត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ

១៣. អង្គជំនុំជម្រះសាលាដំបូងស្នើភាគីផ្តល់ឱ្យខ្លួននូវ"បញ្ជីឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿងដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយត្រូវបង្ហាញនូវអត្តសញ្ញាណឱ្យបានសមស្របតាមរយៈលេខឯកសារយោង ចំណងជើង ភាសាដែលមាន ហើយត្រូវពន្យល់ដោយសង្ខេបអំពីលក្ខណៈនិងខ្លឹមសាររបស់វា"[13]។ មេធាវីការពារក្តីបានភ្ជាប់ឧបសម្ព័ន្ធមួយដែលចុះបញ្ជីនូវឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងរួចហើយ (រួមទាំងឯកសារនានាដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ) គិតមកដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១ នៅក្នុងតារាង Excel table ។ បញ្ជីឯកសារនេះផ្តល់នូវព័ត៌មានដែលបានស្នើសុំ លេខយោងរបស់ឯកសារ លេខ ERN របស់ឯកសារ និងអត្ថបទបកប្រែរបស់វា ព្រមទាំងឯកសារដែលពាក់ព័ន្ធនានា ចំណងជើងជាភាសាអង់គ្លេស និងភាសាខ្មែររបស់ឯកសារ ប្រភេទនៃឯកសារ ភាគីដាក់ កាលបរិច្ឆេទនៃការដាក់

---

[13] ដីកា នៅកថាខណ្ឌទី១២ ។

កាលបរិច្ឆេទរបស់ឯកសារ លេខឯកសារដាក់ដោយមជ្ឈមណ្ឌល DC-Cam ភាសារបស់ឯកសារ ប្រភពរបស់ឯកសារ ការសង្ខេបឯកសារ ការបង្កើតកាលបរិច្ឆេទ ចំនួនទំព័រ និងការចាត់ចំណាត់ថ្នាក់ ។ មេធាវីការពារក្ដីស្នើឱ្យពិចារណាថាខ្លួនអាចប្រើឯកសារណាមួយនៅក្នុងសំណុំរឿងសំរាប់មូលហេតុដែលនឹងបញ្ជាក់នៅខាងក្រោម ។

**ខ. ការជូនដំណឹងថាមេធាវីការពារក្ដីមិនតម្រូវ ឬមិនអាចជ្រើសរើសនៅពេលនេះនូវឯកសារជាក់លាក់នៅក្នុងបញ្ជីនេះដែលខ្លួននឹងយកមកប្រើនៅសវនាការឡើយ**

១៤. មេធាវីការពារក្ដីសូមជម្រាបដល់អង្គជំនុំជម្រះសាលាដំបូងថាច្បាប់កម្ពុជា និងវិធានផ្ទៃក្នុងមិនតម្រូវឱ្យមេធាវីការពារក្ដីផ្ដល់បញ្ជីឯកសារ ដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលមេធាវីការពារក្ដីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ បន្ថែមពីលើនេះ ចំណុចនេះមិនបានអនុវត្តនៅក្នុងសំណុំរឿង ០០១ នោះទេ ។ នៅពេលនេះមេធាវីការពារក្ដីមិនអាចជ្រើសរើសឯកសារជាក់លាក់ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅសវនាការបានឡើយ ។ ការដាក់កំហិតសមត្ថភាពរបស់មេធាវីការពារក្ដីក្នុងការប្រើឯកសារណាមួយមិនយុត្តិធម៌ដល់លោក អៀង សារី ឡើយ ។

**១. ច្បាប់កម្ពុជា និងវិធានផ្ទៃក្នុងមិនតម្រូវឱ្យភាគីបង្កើតបញ្ជីឯកសារនៅក្នុងសំណុំរឿង ដែលភាគីមានបំណងដាក់នៅអង្គជំនុំជម្រះនៅសវនាការ ឡើយ**

១៥. វិធាន ៨៧ ចែងក្នុងផ្នែកពាក់ព័ន្ធថា "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អែកលើភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ដេញដោល។ អង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង បើសិនភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះនៅចំពោះមុខភាគី ។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្ថសញ្ញាណយ៉ាងសមស្របក្នុងសវនាការ" ។ វិធាននេះហាក់ដូចជាផ្អែកលើមាត្រា ៣២១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលចែងក្នុងផ្នែកពាក់ព័ន្ធថា "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី...។ តុលាការសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬ

00664466



ដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។ អាស្រ័យហេតុនេះ វិធានទូទៅនៅអវតក និងនៅក្នុងតុលាការកម្ពុជាដទៃទៀត គឺថាសម្ភារៈទាំងឡាយនៅក្នុងសំណុំរឿងអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងអាចសំអាងដោយអង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ។

១៦. វិធាន ៨០(៣) ចែងថា "អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យភាគីទាំងឡាយដាក់ឯកសារតាមពេលកំណត់មុនពេលសវនាការបឋម រួមទាំងឯកសារដូចខាងក្រោមៈ ខ) បញ្ជីវត្ថុតាង ដែលភាគីទាំងឡាយមានបំណងប្រគល់ឱ្យសម្រាប់រឿងក្តីនោះដោយមានពិពណ៌នាត្រួសៗអំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាងទាំងនោះ...ឃ) បញ្ជីឯកសារថ្មី ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានភ្ជាប់សេចក្តីសង្ខេបពីខ្លឹមសារនៃឯកសារនោះ និងបញ្ជីឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿងដែលមានកំណត់អត្តសញ្ញាណសមស្រប[14]។ មានចំណុចសំខាន់ចំនួនពីរត្រូវកត់សំគាល់ទាក់ទងនឹងវិធាននេះ។ ចំណុចទី១ មិនដូចគ្នាព័ត៌មានដទៃទៀតដែលថាអង្គជំនុំជម្រះសាលាដំបូងអាចស្នើសុំអនុលោមតាមវិធាននេះ (បញ្ជីវត្ថុតាងនិងបញ្ជីឯកសារថ្មី) វិធាននេះគ្រាន់តែចែងថាអង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យភាគីឱ្យផ្តល់បញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ។ វិធាននេះមិនបានចែងថា អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យភាគីឱ្យផ្តល់បញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ ។ ហេតុដូច្នេះ នៅក្នុងការតម្រូវឱ្យភាគីផ្តល់បញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[15]ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងតម្រូវហួសពីអ្វីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងទៅទៀត ។ វិធាននេះមិនបានចែងថា បើសិនជាភាគីខកខានមិនបានផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង នោះភាគីមិនអាចប្រើឯកសារពីសំណុំរឿងនៅសវនាការទេ ។

១៧. វិធាន ៨០(៣) មិនអាចបកស្រាយថាជាការតម្រូវឱ្យភាគីផ្តល់បញ្ជីឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅសវនាការទេ ហើយថាជាការហាមឃាត់ភាគីមិនឱ្យប្រើឯកសារដែលមិនមាននៅក្នុងសំណុំរឿងដែរ។ការបកស្រាយបែបនេះ

---

[14] បញ្ជាក់បន្ថែម ។

[15] ដីកា នៅកថាខណ្ឌទី១២ (បញ្ជាក់បន្ថែម) ។

00664467



គឺពិតជាការចាកចេញយ៉ាងច្បាស់ពីមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា:

រហូតដល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត ។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចុះទិដ្ឋការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយត្រូវភ្ជាប់ក្នុងសំណុំរឿង[16] ។

១៨. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា បុព្វកថារបស់វិធានផ្ទៃក្នុងចែងថាវិធានផ្ទៃក្នុងនេះត្រូវបានអនុម័តក្នុងគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា និងអនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ[17] ។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា:

> ហេតុដូច្នេះវិធានផ្ទៃក្នុង បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អវតក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ អវតក ។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណងរបស់ អវតក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អវតក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស ។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតូបករណ៍ចំបង ដែលយើងគួរយកមកពិនិត្យមើលក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អវតក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៅក្នុងវិធានផ្ទៃក្នុង និងក្រមព្រហ្មទណ្ឌកម្ពុជា[18] ។

១៩. នៅក្នុងករណីនេះគេពុំមានមូលហេតុថាហេតុអ្វី "កាលៈទេសៈពិសេសដែលមានតែមួយ" ត្រូវតែ

---

[16] បញ្ជាក់បន្ថែម ។

[17] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក(អបជ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ D55/I/8, ERN: 00219322-00219333 នៅកថាខណ្ឌទី១៣

[18] ដូចខាងលើនៅកថាខណ្ឌទី១៤ (បញ្ជាក់បន្ថែម) ។

ចាំបាច់ចាកចេញពីមាត្រា៣៣៤ នៃក្រមព្រហ្មទណ្ឌនោះទេ[19]។ តាមពិត កាលៈទេសៈពិសេសដែលមានតែមួយនៅក្នុងសំណុំរឿង ០០២ គាំទ្រដល់ការលើកឡើងផ្ទុយដែលថាមេធាវីការពារក្ដីត្រូវតែអាចដាក់ឯកសារទាំងអស់ និងភស្តុតាងដែលខ្លួនយល់ថាមានប្រយោជន៍ដល់ការស្វែងរកការពិត ។ ដូចដែលតុលាការកំពូលកាណាដាបានសម្រេចថាៈ

> វាមានសារៈសំខាន់ណាស់ចំពោះរឿងក្ដីមួយដែលព្រឹត្តិការណ៍បានកើតឡើងរយៈពេល ៤៥ ឆ្នាំមកហើយ ដែលសម្ភារៈភស្តុតាងទាំងអស់ត្រូវតែដាក់នៅចំពោះមុខគណៈវិនិច្ឆ័យ ។ ជាមួយនឹងការកន្លងផុតទៅនៃពេលវេលា វាបានបង្កើននូវការលំបាកក្នុងការស្វែងរកការពិតអំពីព្រឹត្តិការណ៍ៈ ការស្លាប់របស់សាក្សី ឬ គេមិនអាចរកសាក្សីបាន ការសាបរលាបនៃការចងចាំ ហើយភស្តុតាងអាចបាត់ជារៀងរហូតក៏ថាបាន ។ ដូច្នេះវាមានសារៈសំខាន់ដែលភស្តុតាងទាំងអស់ដែលអាចរកបាននៅក្នុងរឿងក្ដីបែបនេះ ត្រូវតែដាក់នៅចំពោះមុខតុលាការ ។ អំណះអំណាងដែលថារឿងក្ដីទាំងអស់ជួបការលំបាកនៅក្នុងការពារជនជាប់ចោទ មិនបានទទួលស្គាល់ការណ៍ដែលថា រឿងក្ដីនេះស្ដែងឱ្យឃើញពីការលំបាកពិតប្រាកដសម្រាប់មេធាវីការពារទទួលបានការពិត ដែលមិនអាចប្រៀបជាមួយរឿងក្ដីដទៃទៀត[20] ។

## ២. ការអនុវត្តកន្លងមកបង្ហាញថាភាគីអាចប្រើសម្ភារៈណាមួយនៅក្នុងសំណុំរឿង ដោយពុំចាំបាច់ដាក់បញ្ជីភស្តុតាងជាមុននោះទេ

២០. នៅក្នុងសំណុំរឿង ០០១ ភាគីមិនត្រូវបានតម្រូវឱ្យផ្ដល់បញ្ជីឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[21]ឡើយ ។ ភាគីត្រូវ

---

[19] ប្រសិនបើមានភាពមិនច្បាស់លាស់ចំពោះការបកស្រាយវិធាន ៨០(៣) ឬ ភាពមិនស្របគ្នាជាមួយមាត្រា ៣៣៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា គោលការណ៍វិមតិសង្ស័យ *in dubio pro reo* ដែលត្រូវតែគោរពអនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា តម្រូវឱ្យការបកស្រាយជាប្រយោជន៍របស់ជនជាប់ចោទ ។

[20] រឿងក្ដី R តទល់ Finta [1994] S.C.R. 701, 707 (Can) (បញ្ជាក់បន្ថែម) ។

[21] សូមមើលករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច 001/18-07-2007-ECCC/TC, ការជូនដំណឹងអំពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈបន្ថែម ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ E5, ERN: 00250117-00250121 នៅកថាខណ្ឌទី ៤ ។ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យភាគីដាក់បញ្ជីវត្ថុតាងតែប៉ុណ្ណោះ (វត្ថុតាង) និងបញ្ជីឯកសារថ្មីដែលភាគីមានបំណងផ្ដល់ឱ្យនៅក្នុងសំណុំរឿង ។ នៅកិច្ចប្រជុំរៀបចំសវនាការ ចៅក្រម Cartwright បញ្ជាក់ថា" សហព្រះរាជអាជ្ញាបញ្ជាក់ថាពួកគេមិន

បានអនុញ្ញាតឲ្យប្រកាសពីគោលបំណងរបស់ខ្លួន ដើម្បីដាក់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅទូទាំងសវនាការ ។ នៅក្នុងអំឡុងពេលកិច្ចប្រជុំពេញអង្គនៃសំណុំរឿង ០០១ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានលើកជាសំណួរ "តើថ្ងៃកំណត់នៅពេលណាសម្រាប់ភាគីប្រកាសបំណងរបស់ខ្លួន ដើម្បីដាក់ភស្តុតាង អាចតាមរយៈការសង្ខេប ឬ ការអានភស្តុតាងនោះ? ខ្ញុំគិតថាការដំណើរការសវនាការ និងសក្ខីកម្មរបស់សាក្សីអាចបង្ហាញផ្លូវពីសេចក្តីត្រូវការនេះ បើសិនជាកើតឡើង ហើយភាគីមិនអាចដឹងពីសេចក្តីត្រូវការនៅពីរ ឬបីថ្ងៃមុនបានទេ ។ សូមអរគុណ ។ ចៅក្រម Lavergne បានឆ្លើយតបៈ

> តាមពិតទៅនៅក្នុងបញ្ហានេះ គឺយើងដឹងហើយថាមានដើមបណ្តឹងរដ្ឋប្បវេណី ឬភាគីមួយចំនួនចង់ដាក់ឯកសារមួយចំនួនឲ្យបានមុន ដែលខ្លួនចង់ឲ្យមានការពិភាក្សានៅក្នុងសវនាការ ។ ហើយក្នុងនោះគឺមិនមានកាលបរិច្ឆេទកំណត់ជាក់លាក់បានកំណត់ទេ ព្រោះឥឡូវយើងគិតថាសវនាការ គឺជាទូទៅអាចធ្វើទៅបានទៅតាមការបត់បែន ទន់ភ្លន់បើអាចធ្វើទៅបាន ។
>
> បើសិនជាខ្ញុំអាចប៉ាន់ប្រមាណមើលឃើញអំពីស្នើសុំនេះមុន គឺជាការល្អ ក៏ប៉ុន្តែបើសិនជាយើងធ្វើបាន គឺភាគីលោកអាចដឹងថា សាក្សីណានឹងត្រូវធ្វើសក្ខីកម្មនៅក្នុងថ្ងៃណា? ហើយលោកអាចរៀបចំឯកសារដែលលោកនឹងដាក់ ដើម្បីឲ្យជួយសាក្សីរូបនោះ ។ ប៉ុន្តែខ្ញុំគិតថាអ្វីនឹងកើតមានឡើង គឺខ្ញុំមិនទាន់ឲ្យចម្លើយជាក់លាក់បាននៅឡើយទេ[22] ។

២១. ចៅក្រម Lavergne ក៏បានបញ្ជាក់ថាៈ

> ចំណុចបន្ទាប់គឺទាក់ទងនឹងសេចក្តីណែនាំពីអង្គជំនុំជម្រះ អំពីទាក់ទងទៅនឹងការជូនព័ត៌មានអំពីភស្តុតាង ដែលខាងភាគីមានបំណងចង់ឲ្យធ្វើការត្រួតពិនិត្យនៅក្នុងសវនាការ។ គឺថាខាងសហព្រះរាជអាជ្ញាបានចោទសួរថា តើនៅពេលទៅដែលត្រូវគួរ

---

មានបំណងផ្តល់ឲ្យវត្ថុណាមួយ ជាពិសេសវត្ថុតាងណាមួយ ក្រៅពីឯកសារស្កេនជាភស្តុតាងដែលអាចរកបាននៅក្នុងសំណុំរឿងដែលរួមទាំងរូបថត ខ្សែរភាយន្ត" តែប៉ុណ្ណោះ ។ ករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច 001/18-07-2007-ECCC/TC, ប្រតិចារិត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ E1/1.1, ERN: 00295179- 00295272 ។ (បញ្ជាក់បន្ថែម) ។

[22] ករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច 001/18-07-2007-ECCC/TC, ប្រតិចារិត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ E1/1.1, ERN: 00295179- 00295272 នៅទំព័រ ៦៦-៦៧ ។

ផ្ដល់ឱ្យអង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាង ដែលគួរត្រូវបានលើកឡើងនៅក្នុងអំឡុងពេលសវនាការ ។ ហើយថាតើដំណើរហ្នឹងត្រូវធ្វើយ៉ាងដូចម្ដេច? អង្គជំនុំជម្រះសាលាដំបូងកត់សំគាល់ទៅតាមវិធាន ៩២ នោះថាភាគីអាចធ្វើសន្និដ្ឋានជាលាយលក្ខណ៍អក្សរ រហូតដល់ការបិទការពិភាក្សាដេញដោល ។ អញ្ចឹងហើយការជូនដំណឹងអំពីភស្តុតាងដែលភាគីយល់ឃើញថាគួរត្រូវបានលើកឡើង ដើម្បីធ្វើការត្រួតពិនិត្យនោះគឺត្រូវធ្វើឡើងនៅក្នុងសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ។ គឺនេះអាស្រ័យទៅតាមស្មារតីនៃវិធាន ៩២ ដូច្នេះហើយ ទោះបីជាការជូនដំណឹងហ្នឹងមិនបានផ្ដល់ជូនក៏ដោយ ភាគីក៏អាចជូននូវការជូនដំណឹងអំពីភស្តុតាង ដែលខ្លួនមានបំណងលើកឡើងនៅក្នុងអំឡុងពេលសវនាការនោះ សម្រាប់ក្នុងគោលបំណងនៃការបកប្រែនេះឯង គឺថាឯកសារហ្នឹងគួរតែត្រូវបានទទួលមុន ដូច្នេះវាមានប្រយោជន៍ជាង ។ ហើយអង្គជំនុំជម្រះក៏ឱ្យភាគីនីមួយៗចង់ធ្វើការចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវភាសាណាមួយ ដែលជាភាសាការងារ ដែលចង់ឱ្យបកប្រែឯកសារនោះ[23]។

២២. មេធាវីការពារក្ដីនៅក្នុងសំណុំរឿង ០០២ មិនត្រូវទទួលបាននូវការធ្វើប្រព្រឹត្តកម្មខុសគ្នាពីក្រុមការពារក្ដីនៅក្នុងសំណុំរឿង ០០១ ឡើយ។ លោក អៀង សារី មានសិទ្ធិជាមូលដ្ឋានដែលត្រូវទទួលបាននូវការប្រព្រឹត្តភាពស្មើគ្នានៅចំពោះមុខច្បាប់ ។ សិទ្ធិនេះបានផ្ដល់ឱ្យគាត់ដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងមួយផ្នែកថា "ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបមានភាពស្មើគ្នានៅចំពោះមុខច្បាប់..."[24]។ សិទ្ធិនេះត្រូវបានចែងបន្ថែមទៀតនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ដែលចែងនៅក្នុងមាត្រា ៣ ថា "បណ្ដឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀត"។ សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា ៧ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងមាត្រា ១៤ និងមាត្រា ២៦ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែល អវតក ត្រូវតែគោរពអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា[25]។

---

[23] ដូចខាងលើ នៅទំព័រ ៧២-៧៣ ។

[24] បញ្ជាក់បន្ថែម ។

[25] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១ ។ អវតក ត្រូវតែគោរពសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញា ICCPR អនុលោមតាមមាត្រា ១៣ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក ។

00664471



២៣. ដោយសារអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង00១ និង00២ ជាអង្គជំនុំជម្រះតែមួយដូចគ្នា នោះនីតិវិធីរបស់អង្គជំនុំជម្រះនេះក៏ត្រូវតែដូចគ្នាដែរ[26]។ ការតម្រូវមេធាវីការពារក្ដីក្នុងសំណុំរឿង 00២ឱ្យកំណត់យកសម្ភារៈទាំងអស់ដែលពួកមានបំណងប្រើនៅមុនសវនាការជំនុំជម្រះក្ដី ជាបន្ទុកមួយបន្ថែមទៀតដល់មេធាវីការពារក្ដីព្រោះមេធាវីការពារក្ដីក្នុងសំណុំរឿង 00១ មិនត្រូវបានតម្រូវឱ្យធ្វើដូច្នេះឡើយ ហើយករណីបែបនេះ ក៏មិនមានចែងក្នុងវិធានផ្ទៃក្នុងដែរ។

**៣. នៅដំណាក់កាលនេះ វាមិនអាចទៅរួច ហើយក៏មិនមែនជាការប្រព្រឹត្តត្រឹមត្រូវស្របតាមក្រមសីលធម៌ដែរ ក្នុងការដាក់កម្រិតលើឯកសារដែលមេធាវីការពារក្ដីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅសវនាការ ។**

២៤. មេធាវីការពារក្ដីនឹងមិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយវីរិយភាពបានទេ[27] ប្រសិនបើខ្លួនត្រូវបានគេដាក់កំហិតចំពោះសម្ភារៈដែលខ្លួនអាចរកបាន ដើម្បីដាក់នៅចំពោះអង្គជំនុំជម្រះ

---

[26] *ករណី អៀង សារី* 00២/១៩-0៩-២00៧-អវតក/កសចស (អបជ៧១), សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនព្រមទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅកាន់សេចក្ដីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងការអង្កេតបន្ថែម តាមវិធាន៦៦ និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ D390/1/2/4, ERN: 00601705-00601717, ក្នុងករណីដែលអង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិទទួលបានការប្រព្រឹត្តស្មើភាពគ្នាតម្រូវឱ្យគេអនុញ្ញាតឱ្យមេធាវីការពារក្ដីក្នុងសំណុំរឿង00២ ឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានស្ថាពររបស់ កសព ព្រោះមេធាវីការពារក្ដីក្នុងសំណុំរឿង00១ បានទទួលសិទ្ធិបែបនេះ។

[27] មេធាវីការពារក្ដី ត្រូវបានតម្រូវឱ្យបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយវីរិយភាព ដើម្បីការពារផលប្រយោជន៍កូនក្ដីរបស់ពួកគេ ។ *Black's Law Dictionary* ឱ្យនិយមន័យពាក្យវីរិយភាពថាជា “ការយកចិត្តទុកដាក់ដែលគេរំពឹងទុកដោយសមហេតុផលពីអ្នកដែលមានចេតនាបំពេញលក្ខណ្ឌច្បាប់ ឬក៏ដើម្បីអនុវត្តកាតព្វកិច្ច និងត្រូវបានអនុវត្តជាធម្មតាដោយអ្នកដែលមានចេតនាបំពេញលក្ខខណ្ឌច្បាប់ ឬក៏ដើម្បីអនុវត្តកាតព្វកិច្ច ”។ BLACK'S LAW DICTIONARY 468 (7th ed. 1999)។ តុលាការ ICTY បានលើកឡើងថាគោលបំណងនៃការផ្ដល់សិទ្ធិមួយចំនួនដល់ជនជាប់ចោទ តាមលក្ខន្តិកៈរបស់តុលាការនេះគឺ “ជនជាប់ចោទត្រូវតែអាចអនុវត្តប្រកបដោយវីរិយភាពក្នុងការប្រើសិទ្ធិទាំងនោះ” ។ JUDGE RICHARD MAY & MARIEKE WIERDA, INTERNATIONAL CRIMINAL EVIDENCE 306, (Transnational Publishers Inc., 2002), ពិភាក្សាពីរឿងក្ដីរដ្ឋអាជ្ញា តទល់នឹង. *Tadić*, IT-94-1-A, សាលដីកាលើញត្តិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍សុំពន្យាពេលកំណត់ និងការទទួលយកភស្តុតាងបន្ថែម, ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨ ។ ដូចដែលអ្នកប្រាជម្នាក់បានកត់សម្គាល់ថា៖ “ទាក់ទងនឹងពេលវេលា និងមធ្យោបាយ កម្រិតនៃការយកចិត្តទុកដាក់មួយផ្នែកនៃការការពារក្ដី ត្រូវបានគេរំពឹងទុក និងតម្រូវឱ្យមាន ។ មេធាវីការពារក្ដីអាចតវ៉ាពីការរំលោភសិទ្ធិរបស់ពួកគេលុះត្រាតែពួកគេបានធ្វើអ្វីគ្រប់យ៉ាងដែលតម្រូវដោយច្បាប់ក្នុងស្រុកដើម្បីទទួលបានការពន្យាពេល ឬមធ្យោបាយតែប៉ុណ្ណោះ”។ HUMAN RIGHTS IN CRIMINAL PROCEEDINGS 214 (Oxford University Press, 2005) ។ (បញ្ជាក់បន្ថែម)។

00664472



សាលាដំបូងនៅក្នុងតំណាក់កាលនេះ ។ មកទល់ពេលនេះ មេធាវីការពារក្តីមិនទាន់ត្រូវបានគេជូនដំណឹងនៅឡើយទេទាក់ទងនឹងបញ្ហាថា តើសវនាការនៃសំណុំរឿងនេះនឹងត្រូវគេចាត់ចែងដោយរបៀបណានោះ ទោះបីជាមេធាវីការពារក្តីបានស្នើសុំព័ត៌មាននេះពីរលើករួចមកហើយ[28]។ ជាការគោរពដល់សមភាពនៃការតតាំងក្តី ប្រសិនបើ កសព អាចដាក់ឯកសាររបស់ខ្លួន ដូចតាមអ្វីដែលខ្លួនបានស្នើសុំ[29] នោះមេធាវីការពារក្តីក៏ត្រូវតែមានឱកាសដូច កសព ដែរ ដើម្បីបង្ហាញពីសំណុំរឿងរបស់ខ្លួន ។ កសព មានបន្ទុកដាក់ភស្តុតាង និងមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ[30]។ បើសិន កសព ដាក់ឯកសាររបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរហូតដល់ពេលសវនាការចាប់ផ្តើម នោះមេធាវីការពារក្តីនឹងមិនដឹងថាតើសម្ភារះរបស់ កសព អ្វីខ្លះដែលចាំបាច់ត្រូវជំទាស់ ។ ការតម្រូវឱ្យមេធាវីការពារក្តីដាក់សម្ភារះក្នុងពេលនេះនឹងរំលោភដល់សិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានសន្មត់ទុកជាមុនថាគ្មានទោស ប្រសិនបើជាសវនាការជំនុំជម្រះក្នុងសំណុំរឿង០០២ ត្រូវបានរៀបចំចាត់ចែងតាមរបៀបនេះ[31] ព្រោះវាបានផ្លាស់ប្តូរយ៉ាងមានប្រសិទ្ធិភាពនូវបន្ទុកនៃការបង្ហាញភស្តុតាងដោយតម្រូវឱ្យលោក អៀង សារី បង្ហាញពីទស្សនៈ វិស័យនៃការការពារក្តីរបស់គាត់ នៅមុនការដាក់សម្ភារះរបស់ កសព នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ នៅដំណាក់កាលនេះ គឺជាពេលវេលាសក្តិសមបំផុតដែល កសព

---

[28] សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ, ញត្តិរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងជំនុំជម្រះក្នុងសំណុំរឿង០០២ អនុវត្តតាមនីតិវិធី និងសំណើដែលបានកែប្រែ និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ឱ្យភាគីដាក់សម្ភារះរៀបចំសវនាការ, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ E9/3, ERN: 00641756-00641760 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ សំណើរបស់ អៀង សារី សុំពន្យារពេលដាក់បញ្ជីឯកសារ និងភស្តុតាងរបស់គាត់ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០១១, ឯកសារ, ERN: 00655282-00655288 ។

[29] សូមមើល *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អបជអ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធ ១ ២ ៣ ៤ និង៥ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១, ឯកសារ ERN: 00640732-00640736, នៅកថាខណ្ឌ ១៥-២០ ។ កសព បានទទួលស្គាល់ថា "វិធាន២១ (១) នៃវិធានផ្ទៃក្នុងបានពិពណ៌នាពីដំណើរការនីតិវិធីនៅ អវតក ថាជាគោលការណ៍ចំពោះមុខដែលជាការពិពណ៌នាបុរាណនៃច្បាប់ព្រហ្មទណ្ឌតាមប្រព័ន្ធច្បាប់ common law "។ អនុស្សារណៈអន្តរការិយាល័យដែល កសព ផ្ញើទៅអ្នកស្រី Susan Lamb អ្នកសម្របសម្រួលតុលាការ និង សំណើសុំធ្វើវិសោធនកម្មវិធានចំនួន២ (១)ការដាក់ភស្តុតាងនៅសវនាការ (២)ការសាកសួរជនជាប់ចោទ និងសាក្សី ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០, ទំព័រទី៦។

[30] សូមមើលវិធាន៨៧ (១)។

[31] សូមមើលរដ្ឋធម្មនុញ្ញ, មាត្រា៣៨, ច្បាប់ស្តីពីការបង្កើត អវតក, មាត្រា ៣៥, វិធាន២១ (១) (ឃ)។

00664473



ត្រូវផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវព័ត៌មាននេះ ព្រោះ កសព ជាអ្នករៀបចំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០២ ។ បើតាមការប៉ាន់ស្មាន កសព អាចបានរៀបចំសេចក្តីសន្និដ្ឋានទាំងនេះ ដោយភ្ជាប់ឯកសារទៅនឹងការចោទប្រកាន់ផ្សេងជាច្រើនរបស់ខ្លួន។

២៥. ប្រសិនបើគ្មាន "បញ្ជីឯកសាររបស់ កសព" ការជំនុំជម្រះក្តីនឹងអនុវត្តតាមប្រព័ន្ធដែលដឹកនាំដោយចៅក្រមបែបបុរាណ ។ ចៅក្រមនីមួយៗនៅអង្គជំនុំជម្រះសាលាដំបូងត្រូវតែអានសម្ភារៈទាំងអស់នៅក្នុងសំណុំរឿង និងក្នុងឃ្លាំងផ្ទុកឯកសាររួមនៅមុនការចាប់ផ្តើមសវនាការ[32]។ អង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យមើលសំណុំរឿងអស់រយៈពេល ៦ខែកន្លងមកហើយ ពោលគឺចាប់តាំងពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ដើម្បីអនុវត្តកាតព្វកិច្ចនេះ[33]។ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចជាវិជ្ជមានដើម្បីបង្កើតអង្គហេតុឱ្យបានពេញលេញនៅគ្រប់រឿងក្តីទាំងអស់[34]។ មេធាវីការពារក្តីមិនអាចដឹងថា តើសម្ភារៈអ្វីខ្លះដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកជាសម្ភារៈពាក់ព័ន្ធ និងមានតម្លៃអាចបង្ហាញផ្លូវនោះទេ ហើយមេធាវីការពារក្តីក៏មិនអាចដឹងថាតើសម្ភារៈបន្ថែមអ្វីខ្លះដែលខ្លួនត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីបន្ថែមលើភស្តុតាងរបស់អង្គជំនុំ

[32] សាស្ត្រាចារ្យ Damaška កត់សម្គាល់បញ្ហាមួយចំនួនដែលកើតឡើងនៅពេលដែលចៅក្រមមិនដឹងច្បាស់ពីការដាក់សំណួរទៅសាក្សី៖ ដើម្បីធ្វើឱ្យដំណើរការសួរយកចម្លើយមានប្រសិទ្ធិភាព តម្រូវឱ្យអ្នកចោទសួរដឹងច្បាស់ពីប្រធានបទដែលត្រូវចោទសួរ។ ប៉ុន្តែចំពោះករណីបច្ចុប្បន្ន ចៅក្រម Anglo-American រូបនេះបានដឹងបន្តិចបន្តួចប៉ុណ្ណោះអំពីអង្គហេតុនៃរឿងក្តីដែលគាត់កំពុងដោះស្រាយ ។ ប្រសិនបើស្ថានភាពបច្ចុប្បន្ននេះនៅតែបន្ត ការចោទសួររបស់គាត់គ្មានបានអ្វីលើសពីការពិពណ៌នាបន្តិចពីសាក្សីឡើយ ។ មេធាវីដែលបានដឹងព័ត៌មានដែលសាក្សីមាន នឹងអាចចោទសួរបានល្អជាង ហើយនឹងចាប់ផ្តើមតួនាទីដ៏លើសលប់របស់ពួកគេក្នុងដំណើរការសាកសួរ ។ ការចោទសួរបឋមមិនបានដិតដល់របស់អង្គចៅក្រម នឹងធ្វើឱ្យប៉ះពាល់ដល់ផែនការរបស់ពួកគេក្នុងការបង្ហាញភស្តុតាងច្បាស់នឹងតាមលំដាប់លំដោយ ។ ភាពអាចទទួលយកបាននឹងរិតតែមានការលំបាក៖ ការរៀបរាប់ដោយសេរីជាងនេះដែលផ្តើមពីការចោទសួរដ៏ទូលំទូលាយរបស់អង្គចៅក្រម នឹងដាក់បញ្ចូលសម្ភារៈដែលរឹតតែមិនអាចទទួលយកបានថែមទៀតទៅក្នុងសំណុំរឿងជាងបច្ចេលទេសចោទសំណួរដែលមិនទូលំទូលាយដោយមេធាវីការពារក្តី ។ Mirjan Damaška, *The Uncertain Fate of Evidentiary Transplants: Anglo-American and Continental Experiments*, 45 AM. J. COMP. L. 839, 850 (1997)។

[33] វិធាន៦៩ (៣) អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលសំណុំរឿងដើម្បីរៀបចំទុកជាមុននៅពេល ដែល កសចស ចេញដីកាដំណោះស្រាយ។

[34] *ករណី* Abraham S. Goldstein & Martin Marcus, *The Myth of Judicial Supervision in Three "Inquisitorial" Systems: France, Italy, and Germany*, 87(2) Yale L.J. 240, 246 (1977)។

ជម្រះសាលាដំបូង និងជួយអង្គជំនុំជម្រះនេះស្វែងរកការពិតបានឡើយ លុះត្រាតែអង្គជំនុំជម្រះសាលាដំបូងបង្ហាញភស្តុតាងនៅសវនាការ ឬផ្តល់ឱ្យភាគីជាមុននូវបញ្ជីសម្ភារៈដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងបង្ហាញ ។ ដូចចៅក្រម Lavergne បានកត់សម្គាល់ក្នុងសំណុំរឿង ០០១ ថា៖ “អង្គជំនុំជម្រះសាលាដំបូង...ដែលទទួលខុសត្រូវអនុវត្តដំណើរការនីតិវិធី...នឹងមានតួនាទីបឋមក្នុងការបង្ហាញភស្តុតាងក្នុងសវនាការ។ ប៉ុន្តែក្នុងករណីដែលភាគីមួយឬភាគីច្រើនមានបំណងលើកមកសំអាងភស្តុតាងជាក់លាក់ណាមួយ ដែលមិនទាន់ត្រូវបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង ភស្តុតាងនេះអាចត្រូវបានសង្ខេប ឬអានដោយភាគីមួយ ឬភាគីច្រើននោះ[35]។

**គ.ការជូនដំណឹងអំពីភាពខ្វះសមត្ថភាពរបស់មេធាវីការពារក្តីក្នុងការផ្តល់ឱ្យបានពេញលេញនូវ “តារាងភស្តុតាងជាឯកសារ” សម្រាប់ឯកសារដែលមានក្នុងសំណុំរឿងរួចហើយ។**

២៦. នៅពេលនេះមេធាវីការពារក្តីមិនអាចផ្តល់ “**តារាងភស្តុតាងជាឯកសារ**” ដែលមានសម្ភារៈទាំងអស់ដែលបច្ចុប្បន្ននេះមានក្នុងសំណុំរឿងបានទេ ហើយដូចដែលបានលើកឡើងពីខាងលើ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ច្បាប់ជាធរមានមិនបានតម្រូវឱ្យមេធាវីការពារក្តីផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវតារាងបែបនេះឡើយ ។ មេធាវីការពារក្តីកត់សម្គាល់ឃើញទៀតថាដីកាដំណោះស្រាយបានយោងទៅលើឯកសារជាច្រើនក្នុងសំណុំរឿង ដើម្បីគាំទ្រដល់ការសន្និដ្ឋានផ្នែកអង្គច្បាប់ និងអង្គហេតុរបស់ខ្លួន ។ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងមានរួចជាស្រេចទៅហើយនូវព័ត៌មានដែលអង្គជំនុំជម្រះសាលាដំបូង បានស្នើឱ្យភាគីផ្តល់ឱ្យទាក់ទងនឹងសម្ភារៈដែលបានលើកឡើងក្នុងដីកាដំណោះស្រាយ ដែលមានទំនាក់ទំនងរវាងឯកសារទាំងនេះ និងបញ្ហាជាភស្តុតាងដែលពាក់ព័ន្ធរបស់វា ។

២៧. ចំនួនឯកសារសរុបនៅក្នុងសំណុំរឿងបានកើនឡើងស្ទើររាល់ថ្ងៃ ។ នៅពេលនេះមានឯកសារប្រហែល ៧០,០០០ ឯកសារនៅក្នុងសំណុំរឿង។ ឯកសារទាំងនេះមិនត្រឹមតែរួមបញ្ចូលសម្ភារៈដែល បានមកពីការស៊ើបអង្កេតប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងឯកសារដែលដាក់ដោយភាគី និងតារាងច្បាប់យុត្តិសាស្ត្រដែលភាគីបានលើកលើកមកសំអាង និងអនុស្សរណៈ ដីកាបង្គាប់ និងសេចក្តីសម្រេចនានាដោយអង្គជំនុំជម្រះសាលាដំបូង ។ មានឯកសារជាច្រើននៅក្នុងសំណុំរឿង

[35] ករណី កាំង ហ្គេចអ៊ាវ, សំណុំរឿង០០១/១៨-០៧-២០០៧- អវតក/អជសដ, ប្រតិចារិក, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩, ឯកសារ E1/1.1, ERN: 00295179- 00295272, ទំព័រទី៦៤។

បើទោះបីជាមិនមែនទាំងអស់ក៏ដោយ ត្រូវបានបកប្រែ និងមានជាភាសាខ្មែរ បារាំង និងអង់គ្លេស។ ឯកសារដទៃទៀតក៏មានជាភាសាផ្សេងទៀតផងដែរ ដូចជាភាសាអាឡឺម៉ង់ ស៊ុយអែត និង វៀតណាម ។ ឯកសារដែលមានក្នុងសំណុំរឿង មិនត្រូវបានគេទទួលស្គាល់ទៅតាមអ្វីដែល ឯកសារទាំងនោះទាក់ទងនឹងប្រធានបទភស្តុតាងឡើយ ។

២៨. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធលើសំណើរបស់មេធាវីការពារក្តីសុំពន្យាពេលវេលាដោយឈរលើមូលដ្ឋានថា មេធាវីការពារក្តីបានពិនិត្យមើលសំណុំរឿងចាប់តាំងពីការចាប់ផ្តើមការស៊ើបសួរមកម្លេះ[36]។ ប៉ុន្តែការសន្និដ្ឋានបែបនេះ ជាការសន្និដ្ឋាមួយដែលងាយស្រួលពេកហើយ ហើយក៏មិនបានពិចារណាពីស្ថានភាពជាក់ស្តែងដែរ ។ ទោះបីជាមេធាវីការពារក្តីបានពិនិត្យមើលសំណុំរឿងចាប់តាំងពីការចាប់ផ្តើមការស៊ើបសួរ ឬច្បាស់ជាងនេះទៀត ចាប់តាំងពីសហមេធាវីការពារក្តីត្រូវបានចាត់តាំងឱ្យការពារក្តីលោក អៀង សារី និងសមាជិកទាំងអស់ក្នុងក្រុមមេធាវីការពារក្តីត្រូវបានជួលឱ្យមកបំពេញការងារក៏ដោយ ក៏មិនមានសម្ភារៈទាំងអស់ក្នុងសំណុំរឿងអាចត្រូវបានពិនិត្យមើលនៅពេលចាប់ផ្តើមការស៊ើបអង្កេតដែរ ។ សម្ភារៈត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងបន្តិចម្តងៗក្នុងរយៈពេលបីឆ្នាំកន្លះមកនេះ ។ សម្ភារៈភាគច្រើនមិនត្រូវបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងជាភាសាដែលក្រុមមេធាវីការពារក្តីទាំងមូលអាចយល់បានឡើយ ដូច្នេះមេធាវីការពារក្តីត្រូវរង់ចាំការបកប្រែ។ មេធាវីការពារក្តីមានសមាជិកតិច និងមានភារកិច្ចមុនសវនាការដែលត្រូវបំពេញជាច្រើនទៀត ។ មេធាវីការពារក្តីមិនអាចលះបង់ពេលវេលាទាំងអស់របស់ខ្លួនទៅពិនិត្យមើលសម្ភារៈក្នុងសំណុំរឿងឡើយ។ ឧទាហរណ៍ ក្នុងសំណុំរឿង០០២ មានបញ្ហាយុត្តាធិការស្មុគស្មាញជាច្រើនដែលជាចំណាប់អារម្មណ៍ដំបូង ដែលត្រូវតែបានដោះស្រាយឱ្យបានទាន់ពេលវេលា[37]។ ប្រសិនបើមេធាវីការពារក្តីមិនបានលើកបញ្ហាទាំងនេះទេ នៅពេលក្រោយមកទៀត

---

[36] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស, ចម្លើយតបទៅកាន់សំណើសំណើរបស់លោក អៀង សារី សុំផ្តល់ឱ្យមេធាវីការពារក្តីនូវតារាងវិភាគភស្តុតាង, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០, E9/16/4, ERN: 00657167-00657169។

[37] សូមមើលឧទាហរណ៍ *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) សំណើរបស់ អៀង សារី ស្របតាមសេចក្តីសម្រេចលើសំណើជាបន្ទាន់របស់សហមេធាវីការពារក្តីសុំពន្យារពេលសមស្រប ដើម្បីដាក់ការតវ៉ាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨ C/22/I/26, ERN: 00177265-00177280 ។ *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ D240, ERN: 00401925-00401940 ។ *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស

មេធាវីការពារក្ដីអាចប្រឈមនឹងការអះអាងអំពីការផ្ដល់ជំនួយមិនមានប្រសិទ្ធិភាព ហើយបញ្ហាទាំងនេះអាចត្រូវបានគេបោះបង់ចោល។ អំណះអំណាងដែលបានលើកឡើងតាំងពីដំបូងទាក់ទងនឹងបណ្ដឹងសារទុក្ខក្នុងសំណុំរឿង០០១ ដែលថា អវតក មិនមានយុត្តាធិការលើ ឌុច ព្រោះ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ គឺជាឧទាហរណ៍មួយ[38]។ កសព បានលើកឡើងថាការជំទាស់ខាងយុត្តាធិការនេះ ត្រូវបានធ្វើឡើងដោយយឺតពេល[39]។

២៩. ក្នុងអំឡុងពេលនៃការស៊ើបសួរ មេធាវីការពារក្ដីបានស្នើ កសចស ផ្ដល់ឱ្យខ្លួននូវព័ត៌មានដែលអាចជួយមេធាវីការពារក្ដីក្នុងការចងក្រងព័ត៌មាន ដែលអង្គជំនុំជម្រះសាលាដំបូងស្នើសុំនៅពេលនេះ ប៉ុន្តែ កសចស មិនបានធ្វើតាមការស្នើសុំរបស់មេធាវីការពារក្ដីឡើយ ។ ជាបឋម មេធាវីការពារក្ដីបានស្នើ កសចស បង្ហាញវិធីសាស្ត្រក្នុងការស៊ើបសួររបស់ខ្លួន រួមទាំងបញ្ហាផ្សេងៗទៀត ដូចជាការរៀបចំផែនការរបស់ កសចស និងយុទ្ធសាស្ត្រទូទៅនៃការស៊ើបសួរ ការស្វែងរក និងការវិភាគភស្តុតាងដោះបន្ទុកដោយ កសចស ដែលគ្របដណ្ដប់លើព័ត៌មានទាក់ទងនឹងទ្រឹស្ដីផ្សេងគ្នានៃព្រឹត្តិការណ៍ដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវបានពិចារណាដោយ កសចស និងព័ត៌មានថាតើទ្រឹស្ដីផ្សេងៗទាំងនេះត្រូវបានប្រែក្លាយទៅជាប្រព័ន្ធមួយសម្រាប់

---

ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ D378, ERN: 00498540-00498552 ។ *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នៃការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ D379, ERN: 00511576-00511589 ។ ករណី *អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ERN: 00208225-00208240 ។ ករណី *អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នៃការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌជាថ្នាក់លើ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ D345/2, ERN: 00475513-00475527 ។ ករណី *អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នៃឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងមាត្រា ៣ នៃច្បាប់បង្កើត អវតក (បទល្មើសជាតិ) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ERN: 00532798-00532812 ។

[38] សូមមើលអត្ថបទរបស់ Julia Wallace & Kuch Naren, មេធាវីការពារក្ដីលើកអំណះអំណាងថា ឌុច "មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ" ព្រឹត្តិប័ត្រ *ភ្នំពេញប៉ុស* ចុះផ្សាយនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ នៅទំព័រទី១ ។

[39] សូមមើលអត្ថបទរបស់ James O'Toole & Cheang Sokha ការកំណត់ទោស ឌុច ត្រូវបានសួរដេញដោល ហើយការពិភាក្សាដេញដោលនេះបន្តធ្វើនៅសវនាការលើបណ្ដឹងសារទុក្ខ ព្រឹត្តិប័ត្រ *ភ្នំពេញប៉ុស* ចុះផ្សាយនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ នៅទំព័រទី១ ។

00664477



ការកំណត់អត្តសញ្ញាណ ការប្រមូល និងវិភាគភស្តុតាងដោះបន្ទុកដោយរបៀបណា[40] ។ កសចស បានបដិសេធមិនព្រមផ្តល់ព័ត៌មាន ដែលអាចជួយមេធាវីការពារក្តីក្នុងការវាយតម្លៃភស្តុតាងនៅក្នុងសំណុំរឿងឡើយ[41] ។ បន្ទាប់មកមេធាវីការពារក្តីបានស្នើ កសចស ផ្តល់ឱ្យខ្លួននូវតារាងវិភាគ ដែលជាផ្នែកមួយនៃដីកាដំណោះស្រាយ ដែលភ្ជាប់អង្គហេតុនីមួយៗទៅនឹងភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុកដែលពាក់ព័ន្ធនីមួយៗ និងធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ និងធាតុផ្សំនីមួយៗដែលបង្កើតឱ្យមានទម្រង់នៃការចូលរួម[42] ។ ចំណុចនេះនឹងអាចជួយមេធាវីការពារក្តីបានច្រើន ដើម្បីវាយតម្លៃភស្តុតាងនៅក្នុងសំណុំរឿង ។ ប៉ុន្តែ កសចស បានបដិសេធដោយគ្រាន់តែលើកឡើងថា ដីកាដំណោះស្រាយ "មិនអាចបង្ហាញក្នុងតារាងវិភាគបានទេដោយសារតែដីកាដំណោះស្រាយអាចត្រូវបានគេយកមកអាន នៅពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី...[43]" ។

### ឃ. បញ្ជីបឋមនៃឯកសារថ្មីដែលមេធាវីការពារក្តីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

៣០. មេធាវីការពារក្តីនឹងដាក់បញ្ជីបឋមនៃសម្ភារៈថ្មី ដែលខ្លួនមានបំណងដាក់ជូនអង្គជំនុំជម្រះសាលា

---

[40] សូមមើល*ករណី អៀង សារី* 00២-១៩-0៩-២00៧-អវតក/កសចស សំណើលើកទី៣ របស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២00៩ ERN: 00330819-00330834 ។ *ករណី នួន ជា* 00២-១៩-0៩-២00៧-អវតក/កសចស ការជូនដំណឹងអំពីការចូលរួមជាមួយសំណើលើកទីបីរបស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២00៩ D171/2, ERN: 00337488-00337489 ។ *ករណី ខៀវ សំផន* 00២-១៩-0៩-២00៧-អវតក/កសចស ការជូនដំណឹងអំពីការចូលរួមជាមួយសំណើលើកទីបីរបស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ តាមវិធាន ៥៥-១០ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២00៩ D171/3, ERN: 00379332-00379333 ។

[41] ជាយថាហេតុ កសចស បានឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីសុំព័ត៌មាននេះ ប៉ុន្តែការឆ្លើយតបនេះមិនច្បាស់ និងមានលក្ខណៈទូទៅពេក ពិបានឱ្យមេធាវីការពារក្តីយកមកប្រើបាន ។ *ករណី អៀង សារី* 00២-១៩-0៩-២00៧-អវតក/កសចស ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើរបស់ អៀង សារី "សុំបំពេញកិច្ចស៊ើបសួរ" ទាក់ទងនឹងយុទ្ធសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២00៩ D171/5 ។

[42] *ករណី អៀង សារី* 00២-១៩-0៩-២00៧-អវតក/កសចស សំណើរបស់ អៀង សារី សុំតារាងវិភាគដែលភ្ជាប់អង្គហេតុនីមួយទៅនឹងភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុកនីមួយៗដែលពាក់ព័ន្ធ ធាតុផ្សំនីមួយៗនៃបទល្មើសដែលបានចោទប្រកាន់ និងធាតុផ្សំនីមួយៗដែលបង្កើតបានជាទម្រង់នៃការចូលរួម ដែលជាផ្នែកនៃដីកាដំណោះស្រាយ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២0១0 A372, ERN: 00492598-00492604 ។

[43] *ករណី អៀង សារី* 00២-១៩-0៩-២00៧-អវតក/កសចស ការចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំផ្តល់ឱ្យមេធាវីការពារក្តីនូវតារាងវិភាគភស្តុតាង ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២0១0 A372/1, ERN: 00495269 ។

00664478



ដំបូងតាមកាលបរិច្ឆេទកំណត់របស់អង្គជំនុំជម្រះនេះ ។ បញ្ជីនេះរួមបញ្ចូលទាំងសម្ភារៈដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមនិងសម្ភារៈថ្មីដទៃទៀត ។ មេធាវីការពារក្ដីសូមរក្សាសិទ្ធិបន្ថែមសម្ភារៈទៅក្នុងបញ្ជីនេះនៅដំណាក់កាលក្រោយៗមកទៀត។ វាមិនអាចទៅរួចទេក្នុងការដាក់បញ្ជីសម្ភារៈថ្មីឱ្យបានពេញលេញដែលមេធាវីការពារក្ដី មានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះនោះ ។ បញ្ហានេះបណ្ដាលមកពី (១) មកទល់ពេលនេះមេធាវីការពារក្ដីមិនទាន់ត្រូវបានគេជូនដំណឹងទាក់ទងនឹងបញ្ហាថា តើសវនាការក្នុងសំណុំរឿង០០២ នឹងត្រូវគេរៀបចំបែបណានោះទេ (២) វាមិនអាចទៅរួចបានទេនៅពេលនេះដើម្បីកំណត់ថាឯកសារណាមួយមានក្នុងសំណុំរឿងរួចហើយនោះ (៣) គេមិនអាចពិនិត្យមើលឯកសារទាំងអស់នៅក្នុងឃ្លាំងផ្ទុកឯកសាររួមបានឡើយ និង (៤) មេធាវីការពារក្ដីត្រូវបានគេហាមឃាត់មិនឱ្យបើកការស៊ើបអង្កេតខណៈពេលដែល កសចស ទទួលបានសំណុំរឿង ។ មេធាវីការពារក្ដីត្រូវតែទទួលបានឱកាសដើម្បីបំពេញបន្ថែមបញ្ជីឯកសារថ្មីរបស់ខ្លួននៅតំណាក់កាលក្រោយៗមកទៀត និងមានឱកាសដាក់ឯកសារថ្មីណាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលអាចមានប្រយោជន៍ដល់ការបង្កើតការពិត។

៣១. មេធាវីការពារក្ដី មិនទាន់ត្រូវបានគេផ្ដល់ឱ្យនូវភស្តុតាងដែល កសព និងអង្គជំនុំជម្រះសាលាដំបូងនឹងយកទៅបង្ហាញក្នុងសវនាការនៅឡើយទេ ។ ដោយប្រកាន់ភ្ជាប់នូវការការពារក្ដីប្រកបដោយវិរិយភាព និងដោយសារតែមូលហេតុដូចដែលបានពន្យល់ពីខាងលើ ដែលទាក់ទងនឹងសម្ភារៈដែលមាននៅក្នុងសំណុំរឿងរួចហើយ មេធាវីកាពារក្ដីនៅពេលនេះមិនអាចផ្ដល់នូវបញ្ជីភស្តុតាងថ្មីឱ្យបានពេញលេញដែលខ្លួននឹងយកមកប្រើបានទេ ។

៣២. នៅពេលនេះមេធាវីការពារក្ដីមិនរៀបចំបញ្ជីភស្តុតាងថ្មីឱ្យបានពេញលេញ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានទេ ព្រោះនៅពេលនេះមេធាវីការពារក្ដីមិនអាចកំណត់បានថាតើឯកសារណាមួយដែលមាននៅក្នុងសំណុំរឿងរួចហើយនោះ ។ ការបកប្រែឯកសារនៅតែត្រូវបានគេជូនដំណឹងដល់ភាគីស្ទើររាល់ថ្ងៃ[44]។ នៅពេលថ្មីនេះៗ មិនមានសមាជិកទាំងអស់នៃក្រុមមេធាវី

[44] *ករណី ទួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសង កំណត់ហេតុកិច្ចប្រជុំរបស់សមមិត្ត លេខ១៦៤៖ របាយការណ៍ស្ដីពីការហ្វឹកហ្វឺននាវា D2-15.11, ERN: 00657354-00657356 ដែលបានជូនដំណឹងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ។ *ករណី ទួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសង កំណត់ហេតុកិច្ចប្រជុំរបស់មេបញ្ជាការកងពល អំពីការផលិត ស្ថានការរបស់សត្រូវ និងបញ្ជីឈ្មោះមេបញ្ជាការកងពលធំ IS13.38, ERN: 00656376-00656392 ដែលបានជូនដំណឹងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ។ *ករណី ទួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសង, DC-Cam ការសម្ភាសន៍របស់ ផាន់ សុជា ជាមួយនឹង

ការពារក្តីអាចអានឯកសារទាំងអស់នៅក្នុងសំណុំរឿងបានទេ ។ តាមពិតទៅមេធាវីការពារក្តីមិនអាចកំណត់ថា តើឯកសារថ្មីនីមួយៗដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាឯកសារថ្មីនោះទេ ឬថាតើឯកសារថ្មីនោះអាចមានរួចជាស្រេចនៅក្នុងសំណុំរឿងហើយដែរ ប៉ុន្តែមិនទាន់បកប្រែ ។

៣៣. នៅពេលបច្ចុប្បន្ននេះ មានឯកសារចំនួន១៩,៣៧០ នៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ដូចដែលបានពន្យល់ដោយអង្គបុរេជំនុំជម្រះ៖

ឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមមាន៖

(i) វីដេអូឃ្លីបនៃខ្សែភាពយន្តឯកសារនាសម័យកម្ពុជាប្រជាធិបតេយ្យ។

(ii) ឯកសារពីតុលាការបដិវត្តន៍ប្រជាជនទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩។

(iii) កំណត់ហេតុជាច្រើនដែលបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

(iv) បទសម្ភាសន៍ ។

(v) សម្ភារៈវិភាគទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ។

(vi) អត្ថបទកាសែត សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ជាសាធារណៈ និងការដកស្រង់ពី British Broadcasting Corporation's World Service Summary of World Broadcasts coverage of Far Eastern Affairs និងអត្ថបទសិក្សាទាក់ទងនឹង កម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា និង

(vii) សម្មូហកម្មប្រភពបើកចំហរ វិទ្យុ និងរបាយការណ៍សារព័ត៌មានទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យ និងបញ្ហាពាក់ព័ន្ធទៃទៀតចាប់ពីខែមករា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

<u>ឯកសារទាំងនេះអាចផ្ទុកព័ត៌មានពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត រួមបញ្ចូលទាំង៖</u>

(i) ការស្តាប់ចម្លើយជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ

---

ហែម សៀង នៅភូមិកោះគៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល IS19.43, ERN: 00656345-00656375 ដែលបានជូនដំណឹងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ។

00664480



ការសម្ភាសន៍ជនរងគ្រោះ និងសាក្សីសក្ដានុពល ។

(ii) ព័ត៌មានអំពីស្ថានភាពរស់នៅក្នុងប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

(iii) ព័ត៌មានពីរចនាសម្ព័ន្ធ និងការចាត់តាំងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

(iv) ការលំហូរព័ត៌មានភស្តុតាងរវាងអង្គភាពផ្សេងៗនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

(v) ការបោះពុម្ពផ្សាយជាផ្លូវការដែលផលិតដោយរដ្ឋាភិបាលកម្ពុជាប្រជាធិតេយ្យ និង

(vi) អត្ថបទសារព័ត៌មានអំពីស្ថានភាពក្នុងប្រទេសកម្ពុជាតាំងពីដើមទសវត្ស ១៩៧០ ដល់ ១៩៩០[45]។

៣៤. មេធាវីការពារក្ដីកំពុងតែពិនិត្យមើលឯកសារទាំង ១៩,៣៧០នេះ នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ប៉ុន្តែ មេធាវីការពារក្ដី មិនអាចបំពេញកាតព្វកិច្ចនេះតាមកាលបរិច្ឆេទកំណត់របស់អង្គជំនុំជម្រះសាលាដំបូងបានទេ ។ មេធាវីការពារក្ដីត្រូវពិនិត្យមើលឯកសារនេះផង ហើយត្រូវពិនិត្យមើលឯកសារជាង ៧០,០០០ ទៀតនៅក្នុងសំណុំរឿង ។ ក្នុងអំឡុងពេលនៃការស៊ើបសួរ មេធាវីការពារក្ដីលោក អៀង សារី អ្នកស្រី អៀង ធិរិទ្ធ និងលោក នួន ជា បានស្នើឲ្យ កសចស ពិនិត្យមើលឯកសារក្នុងឃ្លាំងផ្ទុកឯកសាររួមដើម្បីកំណត់ថា តើឯកសារនោះមានផ្ទុកព័ត៌មានដោះបន្ទុកដែរឬអត់ និងដើម្បីដាក់ព័ត៌មានបែបនេះចូលទៅក្នុងសំណុំរឿង[46] ប៉ុន្តែ កសចស បានបដិសេធមិនព្រមបើកការស៊ើបសួរនេះ[47]។ ប្រសិនបើ កសចស មិនបានបដិសេធទេនោះ ភារកិច្ចរបស់មេធាវីការពារក្ដីប្រហែលជាមានភាពធូរស្រាលជាងនេះ ព្រោះសម្ភារៈនេះមួយចំនួននឹងមាននៅក្នុងសំណុំរឿងរួចជាស្រេច

[45] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក(អបជ២៤) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឲ្យស្វែងភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ D164/4/13, ERN: 00402746-00402762 នៅកថាខណ្ឌទី២៩-៣០ ។

[46] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/កសចស សំណើជាបន្ទាន់របស់មេធាវីការពារក្ដីសុំចូលរួមសំណើសុំបំពេញកិច្ចស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ D164, ERN: 00316292-00316302 ។

[47] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ D164/2, ERN: 00343271-00343278 ។

ទៅហើយ ។

៣៥. មេធាវីការពារក្តីមិនអាចដាក់បញ្ជីឯកសារថ្មីឱ្យបានពេញលេញនៅពេលនេះបានទេ ព្រោះមេធាវីការពារក្តីត្រូវបានហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេត នៅពេលដែល កសចស ទទួលបានសំណុំរឿង[48] ។ កសចស បានលើកឡើងថា៖ “នៅចំពោះមុខតុលាការនេះអំណាចក្នុងការបើកការស៊ើបអង្កេត គឺត្រូវបានផ្តល់ឱ្យចំពោះតែសហចៅក្រមស៊ើបអង្កេតឯករាជ្យពីររូបតែប៉ុណ្ណោះ មិនមែនដល់ភាគី ផ្សេងទៀតឡើយ ។ គ្មានបញ្ញត្តិណាមួយអនុញ្ញាតឱ្យភាគីផ្សេងបំពេញកិច្ចស៊ើបសួរជំនួសឱ្យសហចៅក្រមស៊ើបអង្កេតបានឡើយ ហើយករណីនេះក៏មាននៅក្នុងប្រព័ន្ធនីតិវិធីទៃទៀត។ ដូច្នេះអំណាចរបស់ភាគីក្នុងការធ្វើអន្តរាគមន៍ ត្រូវកំណត់ត្រឹមតែការស៊ើបអង្កេតបឋមតែប៉ុណ្ណោះ ដែលចាំបាច់ក្នុងការអនុវត្តន៍ដោយមានប្រសិទ្ធិភាពនូវសិទ្ធិរបស់ពួកគេ ដើម្បីសុំបំពេញកិច្ចស៊ើបសួរ[49]”។ ក្រោយមកទៀត កសចស បានបញ្ជាក់ពីការហាមឃាត់របស់ខ្លួនមិនឱ្យមានការស៊ើបអង្កេតដោយភាគី ដែលនៅពេលនោះ កសចស បានលើកឡើងក្នុងលិខិតព្រមានដែលខ្លួនបានផ្ញើរទៅឱ្យមេធាវីការពារក្តីថា ៖ “តទៅនេះ សហចៅក្រមស៊ើបអង្កេត សូមព្រមានមេធាវីការពារក្តីលោក អៀង សារី ស្របតាមវិធាន៣៨ នៃវិធានផ្ទៃក្នុងថាពួកគេត្រូវបានហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងឡើយ ហើយការរំលោភណាមួយលើការហាមឃាត់នេះ នឹងបណ្តាលឱ្យមានការអនុវត្តទោសប្រឆាំងពួកគេ[50]”។

៣៦. ទើបតែពេលដែល កសចស ឈប់ទទួលបានសំណុំរឿងទេ ទើបមេធាវីការពារក្តីព្យាយាមស្វែងរកឯកសារនានាដែលមាននៅក្នុងសំណុំរឿងរួចហើយ ឬក៏នៅក្នុងផ្នែកសាធារណៈ ដើម្បីផ្តល់បញ្ជីឯកសារបែបនេះទៅអង្គជំនុំជម្រះសាលាដំបូង ។ ករណីនេះត្រូវប្រើពេលវេលាច្រើន ។ វាមានសារៈសំខាន់ដែលថាមេធាវីការពារក្តីត្រូវតែធ្វើការស៊ើបអង្កេតដោយខ្លួន ជាជាងចាំតែពឹងផ្អែកលើភស្តុតាងដែល កសចស ប្រមូលបាន ព្រោះមានភស្តុតាងបញ្ជាក់ថាការស៊ើបអង្កេតរបស់ កសចស

---

[48] សូមមើលឧទាហរណ៍ *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចចេញការព្រមានដោយអនុវត្តតាមវិធាន ៣៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ D367, ERN: 00478513-00478519 នៅកថាខណ្ឌទី៩ ។

[49] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/កសចស អនុស្សរណៈរបស់ កសចស ផ្ញើជូនមេធាវីការពារក្តី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ នៅទំព័រទី២ (បញ្ជាក់បន្ថែម) ។

[50] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចចេញការព្រមានដោយអនុវត្តតាមវិធាន ៣៨ ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០១០ D367, ERN: 00478513-00478519 នៅកថាខណ្ឌទី៩ ។

មានភាពលម្អៀងប្រឆាំងជនជាប់ចោទ ។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេត Marcel Lemonde ត្រូវបានអតីតប្រធានអង្គភាពវិភាគ និងព័ត៌មាននៅ កសចស ចោទប្រកាន់ថាបានបង្ហាញពីចេតនារបស់លោកដល់អ្នកស៊ើបអង្កេតអន្តរជាតិថា៖ “លោកចង់ឲ្យពួកគេស្វែងរកភស្តុតាងដាក់បន្ទុកឲ្យបានច្រើនជាងភស្តុតាងដោះបន្ទុក[51]”។

៣៧. ដោយសារតែមេធាវីការពារក្តី មិនទាន់ដឹងនៅឡើយថាបញ្ជីឯកសារនឹងត្រូវរៀបចំដោយរបៀបណានោះ ទើបនៅពេលនេះមេធាវីការពារក្តីមិនអាចកំណត់អត្តសញ្ញាណនៃភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងរួចហើយបាន ហើយមួយវិញទៀត មេធាវីការពារក្តីមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីវិភាគភស្តុតាងទាំងអស់នៅក្នុងឃ្លាំងផ្ទុកឯកសាររួម និងគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការស៊ើបអង្កេត ហេតុដូច្នេះ មេធាវីការពារក្តីមិនអាចផ្តល់បញ្ជីឯកសារថ្មីឲ្យបានពេញលេញនៅពេលនេះបានទេ ។ មេធាវីការពារក្តីត្រូវតែទទួលបានឱកាសដើម្បីបំពេញបន្ថែមបញ្ជីឯកសារថ្មីរបស់ខ្លួននៅក្នុងដំណាក់កាលក្រោយមកទៀត និងដើម្បីដាក់ភស្តុតាងថ្មីណាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលអាចបង្ហាញផ្លូវដល់ការស្វែងរកការពិត។

## IV. សេចក្តីសន្និដ្ឋាន និងសំណើ

៣៨. តទៅនេះ មេធាវីការពារក្តីសូមដាក់ឧបសម្ព័ន្ធដែលមានបញ្ជីឯកសារនៅក្នុងសំណុំរឿង ។ មេធាវីការពារក្តីយល់ឃើញថាខ្លួនអាចប្រើភស្តុតាងណាមួយដែលមាននៅក្នុងសំណុំរឿងនៅសវនាការ ។ មេធាវីការពារក្តីមិនអាចផ្តល់ “**តារាងភស្តុតាងជាឯកសារ**” ដែលមានសម្ភារៈនេះ តាមការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ ។ ម្យ៉ាងទៀតមេធាវីការពារក្តីសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងដាក់បញ្ជីបឋមនៃភស្តុតាងថ្មី និងសម្ភារៈដែលខ្លួនមានបំណងដាក់នៅអង្គជំនុំជម្រះសាលាដំបូងនៅសវនាការ តាមកាលបរិច្ឆេទកំណត់របស់អង្គជំនុំជម្រះនេះ ។ នៅពេលនេះមេធាវីការពារក្តីមិនអាចដាក់បញ្ជីឯកសារថ្មីបានទេ ហើយមេធាវីការពារក្តីយល់ឃើញថាខ្លួនត្រូវតែទទួលបានឱកាស ដើម្បីបន្ថែមបញ្ជីឯកសារថ្មីរបស់ខ្លួននៅដំណាក់កាលក្រោយៗទៀត

[51] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក(អបជ០១) សំណើរបស់ អៀង សារី សុំផិតចិត្តប្រឆាំងនឹងចៅក្រមស៊ើបអង្កេត Marcel Lemond និងសំណើសុំឲ្យមានសវនាការដេញដោលជាសាធារណៈ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ERN: 00386956-00386968 ឧបសម្ព័ន្ធ ក ទំព័រទី១ ។

និងដាក់ឯកសារថ្មីណាមួយ ទៅអង្គជំនុំជម្រះសាលាដំបូងដែលមានប្រយោជន៍ដល់ការស្វែងការពិត។

**ដូច្នេះ** អាស្រ័យលើមូលហេតុដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យមេធាវីការពារក្តីដាក់ឯកសារដែលមានប្រយោជន៍ដល់ការស្វែងរកការពិត ។ ម្យ៉ាងទៀត មេធាវីការពារក្តីស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកបញ្ជីបឋមនៃភស្តុតាងថ្មីរបស់ខ្លួន និងអនុញ្ញាតឱ្យមេធាវីការពារក្តីបន្ថែមបញ្ជីឯកសាររបស់ខ្លួននៅពេលក្រោយ ភ្លាមៗបន្ទាប់ពីមេធាវីការពារក្តីបានដឹងពីអត្ថិភាពនៃឯកសារថ្មី ឬពីការពាក់ព័ន្ធរបស់សម្ភារៈ នេះ ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**